**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ: ៨៣១ MIH / 2016

# លិខិតអំពាវនាវ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមជម្រាបជូនដល់គ្រប់ក្រុមហ៊ុន សហគ្រាសផលិតទឹកពិសាបរិសុទ្ធដប និងប្រតិបត្តិករ ឬអង្គភាពប្រកបអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតទាំងអស់ឱ្យបានជ្រាបថា ៖ ដោយសារផលប៉ះពាល់នៃរលកកម្ដៅខ្លាំង និងភាពរាំងស្ងួត ក្នុងរយៈពេលប៉ុន្មានថ្ងៃជាប់ៗគ្នានេះ បានបណ្ដាលឱ្យមូលដ្ឋានភូមិ ឃុំ ស្រុក ក្រុង មួយចំនួន ជួបប្រទះនូវកង្វះខាតទឹកស្អាតសម្រាប់បរិភោគ និងទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ ហើយកំពុងតែបង្កជាផលវិបាកធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋយើង។ ក្នុងគោលបំណងរួមចំណែកជួយរំលែកការលំបាកចំពោះមុខរបស់ប្រជាពលរដ្ឋដែលរងគ្រោះដោយបាតុភូតធម្មជាតិនេះ និងយោងតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចតេជោ នាយករដ្ឋមន្ត្រី** ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមអំពាវនាវដល់ថ្នាក់ដឹកនាំ ឬម្ចាស់ក្រុមហ៊ុន សហគ្រាសផលិតទឹកពិសាបរិសុទ្ធដប និងប្រតិបត្តិករ ឬអង្គភាពប្រកបអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតទាំងអស់ (ទាំងរដ្ឋ និងឯកជន) សូមចូលរួមជួយផ្ដល់នូវជំនួយឧបត្ថម្ភជាទឹកបរិសុទ្ធដបគ្រប់ប្រភេទសម្រាប់បរិភោគ ឬទឹកស្អាតសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ ដើម្បីក្រសួងចាត់ចែងយកទៅចែកជូនប្រជាពលរដ្ឋយើងនៅតាមមូលដ្ឋានណាដែលកំពុងប្រឈមនឹងបញ្ហាកង្វះទឹកប្រើប្រាស់ចាំបាច់។ ទន្ទឹមនឹងនេះ ក្រសួងក៏សូមអំពាវនាវផងដែរដល់ក្រុមហ៊ុន សហគ្រាសអាជីវកម្មដទៃទៀត សូមមេត្តាជួយឧបត្ថម្ភគាំទ្រជាថវិកា ឬសម្ភារ មធ្យោបាយដឹកជញ្ជូនតាមគ្រប់រូបភាពគ្រប់លទ្ធភាពដែលអាចធ្វើទៅបាន សម្រាប់ការចូលរួមក្នុងយុទ្ធនាការជួយដោះស្រាយបញ្ហាទឹកជូនប្រជាពលរដ្ឋយើង។

ដើម្បីសម្រួលដល់បញ្ហាទទួល និងបែងចែកជំនួយឧបត្ថម្ភខាងលើនេះ ក្រសួងបានប្រគល់ភារកិច្ចជូនមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត ដើរតួនាទីធ្វើជាចំណុចប្រសព្វនៃការសម្របសម្រួលទំនាក់ទំនង រវាងម្ចាស់ជំនួយ ជាមួយនិងសាលារាជធានី ខេត្ត និងការកំណត់ទីតាំងមូលដ្ឋានជាក់លាក់ជាអាទិភាព ដែលត្រូវដោះស្រាយជាបន្ទាន់នូវការផ្គត់ផ្គង់ទឹកជូនប្រជាពលរដ្ឋ។ ដោយឡែក សម្រាប់រាជធានីភ្នំពេញ និងខេត្តសៀមរាប រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងរដ្ឋាករទឹកស្វយ័តសៀមរាប នឹងចូលរួមសហការធ្វើកិច្ចការនេះជាមួយមន្ទីរឧស្សហកម្ម និងសិប្បកម្មរាជធានីភ្នំពេញ និងសៀមរាប។

ក្នុងនាមថ្នាក់ដឹកនាំក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជំនួសមុខឱ្យប្រជាពលរដ្ឋដែលកំពុងជួបការលំបាក ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសន្ដានចិត្តសប្បុរស និងស្មារតីសាមគ្គី ឯកភាពជាធ្លុងមួយរបស់លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ជាម្ចាស់ក្រុមហ៊ុន សហគ្រាស អាជីវកម្មដ្ឋានទាំងអស់ ដែលបានទទួលយកនូវការអំពាវនាវនេះ និងឆ្លើយតបជាវិជ្ជមានតាមសំណូមពរខាងលើ ដើម្បីជាគុណប្រយោជន៍សម្រាប់ជាតិ និងប្រជាពលរដ្ឋយើង។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៤៤
អ៊ីម៉ែល: mih.smcabinet@gmail.com